**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៧៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានៈ និងប្តូរឈ្មោះ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង ទៅជា វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្របក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១ :** អនុញ្ញាតឱ្យដំឡើងឋានៈ និងប្តូរឈ្មោះ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង ទៅជា " វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង " ហៅកាត់ " វ.ព.ប " និងជាភាសាអង់គ្លេស ( Polytechnic Institute of

Battambang Province ) ហៅកាត់ ( P.I.B )។ វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបងនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង។

មាត្រា ២ : វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង មានភារកិច្ចធ្វើការបណ្តុះបណ្តាល :

- ថ្នាក់វិញ្ញាបនបត្របណ្តុះបណ្តាល សិក្សារយៈពេលខ្លី ក្រោម ១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ សិក្សារយៈពេល ១ឆ្នាំ, ២ឆ្នាំ, ៣ឆ្នាំ ( ៩+១+១+១ )
- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ក្រេឌីត
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ក្រេឌីត។

មាត្រា ៣ : ចំពោះមុខ វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង មានរចនាសម្ព័ន្ធដូចខាងក្រោម :

១- ការិយាល័យរដ្ឋបាល-ផែនការ

២- ការិយាល័យហិរញ្ញវត្ថុ-ឥណទាន

៣- ការិយាល័យអប់រំបណ្តុះបណ្តាល

៤- ដេប៉ាតឺម៉ង់អេឡិចត្រូនិច

៥- ដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា

៦- ដេប៉ាតឺម៉ង់ភាសាបរទេស

នៅថ្ងៃអនាគតវិទ្យាស្ថាននេះ អាចបើកដេប៉ាតឺម៉ង់ ឬសាខា ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា ៤ : លក្ខខណ្ឌទទួលសិស្សឱ្យចូលរៀន :

- ថ្នាក់វិញ្ញាបនបត្រ : បេក្ខជនទាំងពីរភេទជាសិក្ខាកាមសិស្ស និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ : បេក្ខជនទាំងពីរភេទបានរៀនចប់ថ្នាក់ទី ៩ នៃមធ្យមសិក្សាបឋមភូមិ
- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង : បេក្ខជនទាំង ២ភេទ មានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត ៣ ឬបានប្រឡងជាប់ ឬថ្នាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ : បេក្ខជនទាំង ២ភេទ មានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស និស្សិតឱ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

មាត្រា ៥ : នាយកនៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង មានបុព្វសិទ្ធិស្មើនឹងប្រធាននាយកដ្ឋាន និងមាននាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់។

វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យបានទៀងទាត់តាមការកំណត់។

មាត្រា ៦ : វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង កាន់កាប់ និងប្រើប្រាស់ប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវឧបត្ថម្ភថវិកាជាតិ សម្រាប់បណ្តុះបណ្តាល និងមានគណនេយ្យដោយឡែក។

មាត្រា ៧ : និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង និងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

មាត្រា ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងវិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

មាត្រា ៩ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងអប់រំ យុវជន និងកីឡា
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- គ្រប់ខេត្ត-ក្រុង
- ដូចមាត្រា ៨ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ